គំរោងអេកូសន

ECOSORN PROJECT

# សណ្តែកសៀង

(ពូជក្នុងស្រុក)



គំរោងស្តារឡើងវិញលើវិស័យសេដ្ឋកិច្ច និង សង្គមកិច្ចនៅបណ្តាខេត្តនៃតំបន់ពាយ័ព្យ

Economic and Social Re-launch of Northwest Provinces (ECOSORN)

បានទទួលការណែនាំពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

Agricultural Development Denmark Asia

## ១.ការជ្រើសរើសទីកន្លែង:

- ដីមានជីជាតិ
- ដីធូរ និងរាបស្មើល្អ
- ដីខ្ពស់មិនលិចទឹក

## ២.ការជ្រើសរើសពូជសណ្តែកសៀង:

### ក. ពូជនៅក្នុងស្រុក :

- ពូជសំបកផ្លែពណ៌ស B3039 មានរយៈពេល ៩៨ ថ្ងៃ
- ពូជសំបកផ្លែពណ៌ខ្មៅ ពូជក្នុងស្រុកមានរយៈពេល៩២ ថ្ងៃ
- ពូជស្រមូវ រយៈពេល ៩៥ថ្ងៃ
- ពូជស្កា រយៈពេល ៩៥ថ្ងៃ

### ខ. ពូជក្រៅស្រុក :

- ពូជស្បង់លោក ( ថៃឡង់)
- ពូជស្រាល (DT84) រយៈពេល ៨១ ថ្ងៃ

ដែលប្រជាកសិករនិយមចូលចិត្ត ដាំភាគច្រើនជាងគេបានផលច្រើន និង មានរយៈពេលខ្លី ។



### គ. ការរៀបចំដីសំរាប់ដាំសណ្តែកសៀង

- ត្រូវភ្ជួរជំរៅពី ១៥-២៥សម ចំនួន ២ ដង រួច ហើយរាស់បំបែក ដីឱ្យបានបែកល្អិតល្មម
- ភ្ជួរលើកទី១ ត្រូវទុកហាលដីពី ៧ - ១០ ថ្ងៃ ហើយរើសយកស្មៅ និងសំរាមផ្សេងៗ ចេញឱ្យបានស្អាត
- សណ្តែកសៀងត្រូវការដីធូរ, មានជីជាតិល្អ, មិនបៀមមិនជាំទឹក តែដំណាំសណ្តែកសៀងត្រូវការសំណើមដីរហូតដល់ពេលប្រមូលផល ។

### ឃ. ការដាក់ជីទ្រាប់បាត

- ជីកំប៉ុស្ត (ជីធម្មជាតិ) ត្រូវប្រើពី ១០- ២០ តោនក្នុង ១ ហិកតា
- ជី ដេ- អា-ប៉េ ត្រូវប្រើ ១០០ គ.ក្រ ក្នុង ១ ហិកតា
- ជី ប៉ូតាស្យូមប្រើ ១០០ គ.ក្រ ក្នុង ១ ហិកតា ជីទាំងអស់នេះត្រូវ ដាក់នៅពេលភ្ជួររាស់មុនដាំ និងត្រូវភ្ជួរច្របល់រាស់ឱ្យសព្វទៅក្នុងដី ។

### ង. ពេលវេលាដាំដុះ:

-ប្រទេសកម្ពុជាយើងសណ្តែកសៀងត្រូវបានគេកំណត់ ការដាំដុះគឺចាប់ពីពាក់កណ្តាលខែមិថុនារហូតដល់ចុងខែកក្កដាយ៉ាងយូរបំផុត ព្រោះរយៈពេលក្នុងខែកក្កដានេះ មានសន្សើមចុះពេលយប់គ្រាប់សណ្តែកអាចរីកដុះបានក្រោយពេលដាំ និង ស្រោចទឹកបន្តិចបន្តួច ហើយរយៈពេល ៤-៥ ថ្ងៃ ក្រោយមក ពន្លកសណ្តែកសៀងចាប់ផ្តើមដុះចេញជាពន្លកត្រួយ ។

### ច.បច្ចេកទេសដាំ

- ត្រូវយកគ្រាប់ពូជទៅហាលថ្ងៃចំនួន ១ - ២ ម៉ោង ។

ធ្វើ ដូចនេះអាចឱ្យគ្រាប់សណ្តែកឆាប់ដុះបានលឿនពេលដាក់គ្រាប់ទៅក្នុងដី

- តាមក្បូនខ្នាតគេដាំពីជួរមួយ ទៅជួរមួយ ០.៤០ម ទៅ ០.៤៥ម

- ពីគុម្ពមួយ ទៅគុម្ពមួយ ០.២០ម ទៅ ០.៣០ម

- រណ្តៅនីមួយៗ យើងដាក់គ្រាប់ ២ - ៣ គ្រាប់ និងមាន ជំរៅ ៣ - ៤សម. រួចយកដីម៉ដ្ឋ ឬដីលាយដីកំប៉ុស្តលុប ឱ្យជិត ពីលើគ្រាប់សណ្តែក រួចយកដៃទះបន្ថែមស្រាលៗ ដើម្បីធ្វើ ឱ្យគ្រាប់សណ្តែកស្រូបយកសំណើមបានល្អ ។

-បច្ចុប្បន្ននេះកសិករមួយចំនួនបានដាំដោយប្រើម៉ាស៊ីនស្វ័យប្រវត្តិលើចំការធំៗ។

## ៣.ការថែទាំ និងដករំលស់កូនដំណាំ:

-ត្រូវដកកូនរំលស់សណ្តែកចេញខ្លះៗក្នុងរយ:ពេល ១០-១៥ ថ្ងៃ ក្រោយពេលដំណាំដុះ ។

-ក្នុងមួយរណ្តៅ ឬ មួយគុម្ព មានចំនួន ២ ដើម

-ក្រោយពេលដាំចំនួន ១២ - ១៧ ថ្ងៃ ជំរះស្មៅលើកទី ១

-១០-១៥ ថ្ងៃ ក្រោយជំរះលើកទី១ ត្រូវសំអាតស្មៅ លើកទី២

## ៤.ការដាក់ជីបំប៉នលើដំណាំសណ្តែកសៀង

-យើងត្រូវប្រើជីបំប៉នបន្ថែមក្រោយពេលដាំ២០-២៥ ថ្ងៃ

-ត្រូវប្រើជីអ៊ុយរ៉េលើកទីមួយ ៤០-៧០គ.ក្រ ក្នុង ១ហិកតា

-បន្ទាប់ពីបាច ឬ ដាក់ជីរួចយើងត្រូវពូនគល់សណ្តែក ដោយយកដីតាមចន្លោះរងធ្វើឱ្យបានខ្ពស់ដើម្បីបង្កើតជាប្រឡាយ សំរាប់បង្ហូរទឹកចូល។ រយ:ពេលក្រោយការដាំ៣០ថ្ងៃ សណ្តែកចាប់ផ្តើមចេញផ្កាផ្លែមួយៗ ហើយយើងត្រូវ ឧស្សាហ៍ដើរមើលតើមានអ្វីដែលដុះនៅលាយឡំជាមួយដំណាំ យើងត្រូវដកវាចេញឱ្យអស់ ដើម្បីឱ្យសណ្តែកលូតលាស់ ល្អ ។

-ពិនិត្យមើលសត្វល្អិតផ្សេងៗ ដែលមកស៊ីបំផ្លាញ ។ យើងគួរប្រើថ្នាំ អាហ្សូឌ្រីន ( ម៉ូណូក្រូតូហ្វុស) ក្នុងកំរិតពី ២០-៣០ សេសេ លាយទឹកចំនួន ១០លីត្រ ឬ ២ - ៣ សេសេ លាយទឹក ១ លីត្រ ។



## ៥.ការប្រមូលផលសណ្តែកសៀង:

-ក្រោយពេលសណ្តែកមានផ្លែចំណាស់ (ផ្លែស្រគាល)ស្លឹកសណ្តែក វាចាប់ផ្តើមជ្រុះចេញពីដើមម្តងមួយៗរហូតអស់ ពីដើម (៧០-៩០ភាគរយ) ទើបយើងអាចប្រមូលផលបាន

-ធ្វើការត្រួតពិនិត្យកាត់សំអាតស្មៅ វល្លិ បន្លាកុំអោយសើមផ្លែនិងទទួលពន្លឺថ្ងៃស្ងួតល្អងាយស្រួលច្រូតកាត់ដើមពេលប្រមូលផល

-កាត់ដើមសណ្តែកដាក់ជាជួរ ឬយើងអាចពូនជាគំនរធ្វើនៅពេលព្រឹកព្រលឹម ប្រសិនបើដើមនិងផ្លែស្ងួត ល្អពុំមានត្រូវភ្លៀងពីយប់

-ជៀសវាងការប្រមូលផលនៅពេលថ្ងៃក្តៅខ្លាំង វាអាចធ្វើឱ្យ សណ្តែក បែក សំបក គ្រាប់ នាំឱ្យទិន្នផលថយចុះ

-ប្រមូលផលទាំងដើម ទាំងផ្លែមកដាក់លើរាន ឬ កន្លែងដែលយើងបានត្រៀមទុកសំរាប់ហាល

-ការបោកបែនដោយប្រើម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្តិ។

-ក្រោយពេលប្រមូលផលសណ្តែករួចហើយ យើងត្រូវយកកាកសំណល់ និងដើមសណ្តែកទៅបាចពង្រាយលើដីដើម្បីធ្វើជាជីធម្មជាតិ (ធ្វើជីកំប៉ុស្ត, ជីសរីរាង្គ) ដោយភ្ជួរលប់។

-យកគ្រាប់សណ្តែកហាលឱ្យស្ងួត រួចច្រកទុកក្នុងការុងឱ្យបានល្អត្រឹមត្រូវ ។

-បើយើងទុកពូជសំរាប់ឆ្នាំក្រោយយើងត្រូវហាលថ្ងៃឱ្យស្ងួតល្អទ្វេដងឧស្សាហ៍មើលក្រែងសត្វស៊ីសណ្តែក សំណើម ៩-១០% ។

-គ្រាប់សណ្តែកដែលបំរុងទុកធ្វើពូជ ពេលប្រមូលផលភ្លាមត្រូវហាលសំងួតជាបន្ទាន់ជៀសវាងទុកយូររំលង២ឬ៣ថ្ងៃនាំអោយដំណុះថយចុះ។

✱ ✱ ✱ ✱ ✱